ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦ សរណ

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣១ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧

*បងប្អូនកម្មករនិយោជិតនិយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!*

តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចូលរួមជាមួយបងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣១នៃទិវាពលកម្មអន្តរជាតិ១ឧសភា ក្រោមប្រធានបទ «ដើម្បីសន្តិភាព ការងារ មុខរបរ និងអភិវឌ្ឍន៍»។ ទិវាពលកម្មអន្តរជាតិ ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ដើម្បីឧទ្ទិសដល់ចលនាកម្មករអន្តរជាតិដែលបានកើតឡើងនៅក្នុងប្រទេសមួយចំនួនតាំងពី១៣១ឆ្នាំមុន ក្នុងការទាមទារឱ្យមានការកែលម្អលក្ខខណ្ឌការងារនិងជីវភាពរបស់ប្រជាពលករ ហើយព្រឹត្តិការណ៍នេះ បានក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រអន្តរជាតិជារៀងរហូតមក។

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំចាប់តាំងពីថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រហូតមក លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានកំណត់យកជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតផងដែរ។ ទន្ទឹមនឹងនេះ ក្នុងនាមជាសមាជិកអង្គការអន្តរជាតិខាងការងារ យើងមានមោទនភាពណាស់ដោយកន្លងមក កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន ១៣ រួចហើយ ក្នុងនោះមានអនុសញ្ញាស្នូលទាំង ៨ ទៀតផង ដែលនេះគឺជាកត្តាមូលដ្ឋានក្នុងការអនុវត្តសិទ្ធិរបស់កម្មករនិយោជិត ហើយដែលកម្ពុជាក៏ជាប្រទេសមួយដែលបានអនុវត្តតាមបទដ្ឋានអន្តរជាតិខាងការងារដ៏ខ្ជាប់ខ្ជួន ជាពិសេសព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១៤ ត្រូវបានបោះឆ្នោតជាសមាជិកពេញសិទ្ធិនៃក្រុមប្រឹក្សាភិបាលអង្គការអន្តរជាតិខាងការងារ (ILO) សម្រាប់អាណត្តិឆ្នាំ២០១៤-២០១៧ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនិងអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២ និងបានបន្តដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធ

ភាពនៅកម្ពុជា សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភានេះ ដោយផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើកំណែទម្រង់លើគ្រប់វិស័យ។ សន្តិភាពនិងស្ថិរភាពនយោបាយ ត្រូវបានធានារឹងមាំដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនថេរជាមធ្យមប្រចាំឆ្នាំ ៧% អត្រាភាពក្រីក្ររបស់ប្រជាជនត្រូវបានកាត់បន្ថយមក ១៣,៥% និងអត្រាអត់ការងារធ្វើចំនួន ០,៧% ។ កម្ពុជាបានប្ដូរពីប្រទេសដែលមានចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ជាមួយគ្នានេះវិស័យការងារ ការអនុវត្តលក្ខខណ្ឌការងារនិងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈកាន់តែមានភាពប្រសើរឡើងតាមរយៈប្រសិទ្ធភាពនៃប្រព័ន្ធអធិការកិច្ចការងារដែលបានបង្កភាពងាយស្រួល និងទទួលបានការពេញចិត្តពីសំណាក់កម្មករនិយោជិត និងនិយោជក នៅតាមសហគ្រាស និងគ្រឹះស្ថាននានា។ បញ្ហាកូដកម្មបាតុកម្មត្រូវបានអន្តរាគមន៍ដោះស្រាយដល់ទីកន្លែង សំដៅរក្សាបាននូវភាពសុខដុមក្នុងដំណើរការផលិតកម្ម និងទប់ស្កាត់សកម្មភាពល្មើសច្បាប់។ តាមរយៈយន្តការពិភាក្សាជាលក្ខណៈត្រីភាគី ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើងក្នុងឆ្នាំ២០១៧ បានកើនពីចំនួន ១៤០ដុល្លារអាមេរិក ទៅ១៥៣ដុល្លារអាមេរិក កើន៩,៣% បើគិតប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀតកម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់ចំណូលពី១៧០ ទៅ១៨១ដុល្លារអាមេរិកក្នុងមួយខែ។ កម្មករនិយោជិតក៏ទទួលបានអត្ថប្រយោជន៍ពីការបញ្ចុះតម្លៃអគ្គិសនី និងទឹក ព្រមទាំងច្បាប់កតិសន្យាពិសេស ដែលគ្រប់គ្រងលើការជួលផ្ទះឱ្យកម្មករនិយោជិត និងសិស្ស និស្សិត។ ផ្នែករបបសន្តិសុខសង្គម រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យលេខ ០១អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្ដីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ កម្មករកម្មការិនីនឹងទទួលបានរបបថែទាំសុខភាពផងដែរ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានរៀបចំឱ្យមានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

ក្នុងការអភិវឌ្ឍមុខរបរនិងការងារ រាជរដ្ឋាភិបាលបានខិតខំកៀរគរនិងជំរុញការវិនិយោគ ដែលបានបង្កើតឱកាសការងារសម្រាប់កម្មករនិយោជិតរាប់ម៉ឺននាក់ និងបានដោះស្រាយកម្លាំងពលកម្មថ្មីជាច្រើនដែលត្រូវចូលក្នុងទីផ្សារការងារ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវ «គោលនយោបាយជាតិស្ដីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥» ដែលមានចក្ខុវិស័យលើកកម្ពស់ជីវភាព និងភាពថ្លៃថ្នូររបស់ពលរដ្ឋគ្រប់រូបប្រកបដោយសមធម៌ មានភាពស៊ីចង្វាក់គ្នាទៅនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ផងដែរ ដោយផ្ដោតជាសំខាន់លើសសរស្តម្ភបីគឺ *(ទី១) ការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ (ទី២) ការជំរុញការអភិវឌ្ឍជំនាញ និងធនធានមនុស្ស និង(ទី៣) ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ។*

*បងប្អូនកម្មករនិយោជិតនិយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា !*

ជោគជ័យតាមចក្ខុវិស័យ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គឺសុទ្ធតែមានការចូលរួមយ៉ាងសកម្ម និង សុឆន្ទៈពីសំណាក់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតនិងនិយោជក ក៏ដូចជាអង្គការអន្តរជាតិជាដៃគូផងដែរ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនានា ជាពិសេស ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ គណៈកម្មការប្រឹក្សាការងារ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា ដែលកន្លងមកនេះបានរួមចំណែក យ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់កូដកម្ម បាតុកម្ម និងដោះស្រាយវិវាទការងារដោយសន្តិវិធី សំដៅលើកកម្ពស់ ការយោគយល់គ្នាក្នុងទំនាក់ទំនងវិជ្ជាជីវៈ រវាងភាគីពាក់ព័ន្ធទាំងអស់។

ជាមួយគ្នានេះ ខ្ញុំសូមធ្វើការអំពាវនាវចំពោះ ក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ក៏ដូចជា និយោជក កម្មករនិយោជិត សមាគមនិយោជក អង្គការសហជីព ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការ អន្តរជាតិពាក់ព័ន្ធទាំងអស់ សូមយកចិត្តទុកដាក់លើប្រការដូចខាងក្រោម៖

១-បន្តខិតខំលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ជាពិសេសអនុវត្តអនុក្រឹត្យលេខ០១អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃ ច្បាប់ស្តីពីការងារចាប់ពីឆ្នាំ២០១៦ និងកសាងបទដ្ឋានគតិយុត្តសម្រាប់ដាក់ឱ្យអនុវត្តប្រព័ន្ធរបបសោធននៅឆ្នាំ ២០១៧ នេះ ព្រមទាំងរៀបចំដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ស្របតាមស្មារតីព្រះរាជក្រឹត្យលេខ នស/រកត/ ០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់ មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

២-បន្តពង្រឹងយន្តការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព ពង្រឹងសុខដុមនីយកម្ម ទំនាក់ទំនងវិជ្ជាជីវៈ លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់របស់កម្មករនិយោជិត និងនិយោជក ព្រមទាំងបង្កើនប្រសិទ្ធភាពវិធានការការពារទប់ស្កាត់កូដកម្ម បាតុកម្ម និងដោះស្រាយវិវាទការងារដោយសន្តិវិធី និងស្របតាមនីតិវិធីច្បាប់ជាធរមាន បទប្បញ្ញត្តិ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធវិស័យការងារ។

៣-បន្តពង្រឹងការអនុវត្តបទប្បញ្ញត្តិច្បាប់ និងអនុសញ្ញាអន្តរជាតិខាងការងារ និងរៀបចំធ្វើវិសោធនកម្ម ច្បាប់ស្តីពីការងារលើចំណុចមួយចំនួនមានជាអាទិ៍ ប្រភេទកិច្ចសន្យាការងារ ការងារវេនយប់ លក្ខខណ្ឌការងារ សម្រាប់ស្ត្រី និងការហ្វឹកហ្វឺនកូនជាង។ ជំរុញរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា សេចក្តីព្រាង ច្បាប់ស្តីពីនីតិវិធីជម្រះក្តីវិវាទការងារ ព្រមទាំងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ សំដៅធានានិងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ សុខភាព និងសុវត្ថិភាពការងារ និងភាពសុខដុមរមនាក្នុង ទំនាក់ទំនងវិជ្ជាជីវៈ។

៤-បន្តអនុវត្តកម្មវិធីពិភាក្សាប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំ តាមរូបមន្ត និងយន្តការត្រីភាគីដែលគ្រប់ភាគី ទទួលយកបានកន្លងមកក្នុងការកំណត់ការដំឡើងប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង។

៥-បន្តពង្រឹងប្រសិទ្ធភាពសេវាគាំពារ និងការពារសិទ្ធិពលករកម្ពុជានៅបរទេស ព្រមទាំងទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់ ទាំងប្រថុយប្រថាន ដោយចាត់វិធានការម៉ឺងម៉ាត់ចំពោះជនជាមេខ្យល់ ដែលប្រើឧបាយកលអូសទាញ ឬបោកបញ្ឆោតប្រជាពលរដ្ឋ។

៦-កម្មករនិយោជិត យុវជន និងមាតា បិតា គួរបញ្ជូនកូនចៅទៅទទួលការបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ជំនាញ ផលិតភាពការងារ និងមានសមត្ថភាពប្រកួតប្រជែង។

៧-សូមបងប្អូនកម្មករនិយោជិត និងជនរួមជាតិទាំងអស់ អញ្ជើញទៅបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ខាងមុខនេះ ឱ្យបានគ្រប់ៗគ្នា ដើម្បីបំពេញភារកិច្ច និងសិទ្ធិជាពលរដ្ឋនៃប្រទេសមួយដែលប្រកាន់យកនូវលទ្ធិប្រជាធិបតេយ្យ និងដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

៨-សូមយកឱកាសទិវាពលកម្មអន្តរជាតិ ១ ឧសភា នេះធ្វើការរៀបចំសកម្មភាពវប្បធម៌សិល្បៈ ការលំហែកំសាន្តរីករាយ តាមលទ្ធភាព និងលក្ខណៈសម្បត្តិរៀងៗខ្លួន ហើយជៀសវាងឱ្យបានដាច់ខាតនូវការធ្វើសកម្មភាពនានា ដែលនាំឱ្យរំខានដល់សណ្ដាប់ធ្នាប់សាធារណៈ និងបរិយាកាសសប្បាយរីករាយរបស់សង្គមជាតិ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរជូនដល់បងប្អូនកម្មករនិយោជិត និងជនរួមជាតិដែលកំពុងធ្វើការទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាអស់លោក លោកស្រី ជានិយោជក និងនិយោជិតបរទេសជាមន្ត្រីអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលកំពុងស្នាក់នៅ និងបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញថ្ងៃទី ៣១ ខែ ៤ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**